**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងមុខងារសាធារណៈ**
លេខ: ៨៧៥ មស.សសរ

## សេចក្តីសម្រេច
## ស្តីពី
## ការបង្កើតអនុគណៈកម្មការចាក់វ៉ាក់សាំងកូវីដ-១៩
## របស់ ក្រសួងមុខងារសាធារណៈ

## រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកត/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃទីស្តីការគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៣/០១៦ ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៣ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមុខងារសាធារណៈ
- បានឃើញព្រះរាជក្រមលេខនស/រកម/០៣២១/០០៤ ចុះថ្ងៃទី១១ ខែមីនា ឆ្នាំ២០២១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិធានការពារសុខាភិបាលដើម្បីទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ និងជំងឺឆ្លងកាចសាហាវ និង ប្រកបដោយគ្រោះថ្នាក់ធ្ងន់ធ្ងរផ្សេងទៀត
- បានឃើញអនុក្រឹត្យលេខ ៦២ អនក្រ.បក ចុះថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០១៤ ស្តីពីការរៀបចំនិងប្រព្រឹត្តទៅនៃក្រសួងមុខងារសាធារណៈ
- បានឃើញសេចក្តីសម្រេចលេខ ៣៧ សសរ ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០២១ស្តីពីការបង្កើតគណៈកម្មការចំពោះកិច្ចចាក់វ៉ាក់សាំងកូវីដ-១៩ ក្នុងក្របខណ្ឌទូទាំងប្រទេស
- យោងតាមសំណូមពរចាំបាច់របស់ក្រសួង

**សម្រេច**

**ប្រការ១.**-

ត្រូវបានបង្កើត**អនុគណៈកម្មការចាក់វ៉ាក់សាំងកូវីដ-១៩ របស់ ក្រសួងមុខងារសាធារណៈ** ដែលមានសមាសភាពដូចខាងក្រោម៖

| | | |
|---|---|---|
| ១. ឯកឧត្តម **អែម ប៊ុនថុល** | រដ្ឋលេខាធិការ | ប្រធាន |
| ២. លោកជំទាវ **ឆាយ គីមសុទ្ធី** | អនុរដ្ឋលេខាធិការ | អនុប្រធាន |
| ៣. ឯកឧត្តមវេជ្ជ. **ហេង ពិសាល** | ទីប្រឹក្សាក្រសួង | អនុប្រធានអចិន្ត្រៃយ៍ |
| ៤. ឯកឧត្តមវេជ្ជ. **ជ្រឿ សុខលាង** | អគ្គាធិការរង | អនុប្រធាន |
| ៥. ឯកឧត្តម **ហាស់ ប៊ុនថ្លុន** | អគ្គនាយក | អនុប្រធាន |
| ៦. ឯកឧត្តម **ឈុន សុជាតិ** | អគ្គនាយក | សមាជិក |
| ៧. ឯកឧត្តម **យឿន សម្បត្តិ** | អគ្គនាយក | សមាជិក |
| ៨. ឯកឧត្តម **ហែម មគ្គផល** | អគ្គាធិការ | សមាជិក |
| ៩. លោកជំទាវ **លឹម ចន្ទនី** | នាយិការង | សមាជិក |
| ១០. លោកស្រី **ម៉ម ច័ន្ទម៉ារ៉ា** | នាយករងខុទ្ទកាល័យ | សមាជិក |
| ១១. លោក **សូលី វណ្ណប៉ុក** | ប្រធាននាយកដ្ឋាន | សមាជិក |
| ១២. លោក **សួន រស្មី** | ប្រធាននាយកដ្ឋាន | សមាជិក |
| ១៣. លោក **សយ រតនៈ** | ប្រធាននាយកដ្ឋាន | សមាជិក |
| ១៤. លោក **ម៉េង ម៉ង់ចិត** | ប្រធាននាយកដ្ឋាន | សមាជិក |
| ១៥. លោក **សោម សារ៉េត** | ប្រធានលេខាធិការដ្ឋាន | សមាជិក |
| ១៦. លោក លោកស្រី ប្រធានមន្ទីរមុខងារសាធារណៈរាជធានី ខេត្ត | | សមាជិក |

**ប្រការ២.** -

អនុគណៈកម្មការនេះមានតួនាទី និងភារកិច្ច ដូចតទៅ៖

- គ្រប់គ្រង ចាត់ចែង សម្របសម្រួល ជាមួយក្រសួងសុខាភិបាលដើម្បីធានាឱ្យមន្ត្រីរាជការនិងមន្ត្រីជាប់កិច្ចសន្យាទាំងអស់នៃក្រសួងមុខងារសាធារណៈបានចាក់វ៉ាក់សាំងកូវីដ-១៩
- រៀបចំធ្វើសម្រង់ស្ថិតិ បញ្ជីមន្ត្រីរាជការ រៀបចំផែនការ និងប្រតិបត្តិការចាក់វ៉ាក់សាំងកូវីដ-១៩ សម្រាប់មន្ត្រីនៃក្រសួងមុខងារសាធារណៈ ដោយអនុលោមតាមការសម្រេចរបស់គណៈកម្មការចំពោះកិច្ចចាក់វ៉ាក់សាំងកូវីដ-១៩ ក្នុងក្របខណ្ឌទូទាំងប្រទេស
- រៀបចំប្រតិទិនជាមួយ គណៈកម្មការចំពោះកិច្ចចាក់វ៉ាក់សាំងកូវីដ-១៩ ក្នុងក្របខណ្ឌទូទាំងប្រទេស សម្រាប់ចាក់វ៉ាក់សាំងកូវីដ-១៩ ឱ្យមន្ត្រីរាជការនិងមន្ត្រីជាប់កិច្ចសន្យាទាំងអស់នៃក្រសួងមុខងារសាធារណៈបានចាក់វ៉ាក់សាំងកូវីដ-១៩ ទាំងអស់គ្នា
- តាមដាន និងរាយការណ៍វឌ្ឍនភាពការងារចាក់វ៉ាក់សាំងប្រចាំថ្ងៃ និងក្នុងករណីចាំបាច់ រាយការណ៍អំពីស្ថានភាពសុខភាពរបស់អ្នកដែលបានចាក់វ៉ាក់សាំងកូវីដ-១៩ ជូន **រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ** និងជូន **គណៈកម្មការចំពោះកិច្ចចាក់វ៉ាក់សាំងកូវីដ-១៩ ក្នុងក្របខណ្ឌទូទាំងប្រទេស** ឱ្យបានទៀងទាត់
- កិច្ចការផ្សេងៗទៀតដែលពាក់ព័ន្ធនឹងការងារចាក់វ៉ាក់សាំងកូវីដ-១៩។

**ប្រការ៣.-**

នាយកខុទ្ទកាល័យ នាយកសាលាភូមិន្ទរដ្ឋបាល អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ អគ្គនាយកនៃអគ្គនាយកដ្ឋានគ្រប់គ្រងមុខងារសាធារណៈ អគ្គនាយកនៃអគ្គនាយកដ្ឋានគោលនយោបាយមុខងារសាធារណៈ អគ្គាធិការនៃអគ្គាធិការដ្ឋាន គ្រប់អង្គភាពពាក់ព័ន្ធ និងសាមីខ្លួនត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ ព្រហស្បតិ៍ ៥រោច ខែ ចេត្រ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ មីនា ឆ្នាំ២០២១

**រដ្ឋមន្ត្រី**

ព្រុំ-សុខា

**កន្លែងទទួល៖**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យ **សម្តេចតេជោ នាយករដ្ឋមន្ត្រី**
- គណៈកម្មការចំពោះកិច្ចចាក់វ៉ាក់សាំងកូវីដ-១៩ ក្នុងក្របខណ្ឌទូទាំងប្រទេស

  " ដើម្បីជូនជ្រាប "
- ដូចប្រការ ៣

  " ដើម្បីអនុវត្ត "
- ឯកសារ កាលប្បវត្តិ